ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * *

លេខ: ៣២៣/២៣ ឌបឌ

## សេចក្តីប្រកាស

## ស្តីពី

## កំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី ២

## របស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី ២ នៅថ្ងៃអង្គារ ទី៣០ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០ នាទី ដល់ម៉ោង ១០:៤៥ នាទីព្រឹក តាមប្រព័ន្ធអនឡាញ (Zoom)។ វត្តមានរបស់ក្រុមប្រឹក្សាភិបាលនៅក្នុងកិច្ចប្រជុំមានដូចជា៖

| | | |
|---|---|---|
| ១. | លោក នាង វិធី | ប្រធានក្រុមប្រឹក្សាភិបាល/អគ្គនាយកក្រុមហ៊ុន |
| ២. | លោកស្រី លឹម មុយលី | អភិបាលប្រតិបត្តិ |
| ៣. | លោក ហ៊ុយ វ៉ាថារ៉ូ | អភិបាលឯករាជ្យ |
| ៤. | លោក ថៃ វ៉ាន់ថា | អភិបាលមិនប្រតិបត្តិ |
| ៥. | លោក ម៉ាមីបាស៊ា អាសាត សារាហ្វ | អភិបាលមិនប្រតិបត្តិ |

វត្តមានរបស់ភ្ញៀវកិត្តិយសនៅក្នុងកិច្ចប្រជុំមានដូចជា៖

១. ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

២. ភ្ញៀវកិត្តិយសមកពីក្រុមហ៊ុន និងស្ថាប័នផ្សេងៗ និង

៣. ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣

កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២ មានលោក នាង វិធី ប្រធានក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអធិបតីនៃកិច្ចប្រជុំ។ អ្នកសម្របសម្រួលក្រុមហ៊ុនបានស្នើសុំឱ្យម្ចាស់ភាគហ៊ុន និងអ្នកតំណាងភាគហ៊ុនិកទាំងអស់ចុះឈ្មោះរបស់ខ្លួនជាមួយបុគ្គលិកទទួលបន្ទុកចុះឈ្មោះរបស់ក្រុមហ៊ុន។ បន្ទាប់ពីការចុះឈ្មោះរបស់ភាគហ៊ុនិករួចរាល់ហើយ អ្នកសម្របសម្រួលរបស់ក្រុមហ៊ុនបានណែនាំសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដល់ភាគហ៊ុនិកផងដែរ។ បន្ទាប់មក អ្នកសម្របសម្រួលក្រុមហ៊ុនបានប្រកាសកូរ៉ុម និងអញ្ជើញអង្គប្រជុំទាំងមូលគោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ប្រធានក្រុមប្រឹក្សាភិបាល បានថ្លែងសុន្ទរកថាស្វាគមន៍ដើម្បីបើកកិច្ចប្រជុំ។ ជាកិច្ចបន្ទាប់ អភិបាលប្រតិបត្តិ



DBD Engineering Plc. #1298, St.Betong, SK. Kouk Roka, K. Prek Pnov, Phnom Penh, CAMBODIA
Tel: (855)78 700 598, E-mail: services@dbdengineering.com, www.dbdengineering.com

បានធ្វើបទបង្ហាញស្តីពីរបាយការណ៍សង្ខេបសម្រាប់ឆ្នាំ២០២២ និងប្រធានក្រុមប្រឹក្សាភិបាលធ្វើបទបង្ហាញស្តីពីគម្រោងបច្ចុប្បន្នសម្រាប់ឆ្នាំ២០២៣។ បន្ទាប់ពីការធ្វើបទបង្ហាញរបស់អភិបាលទាំងពីរបានបញ្ចប់ អ្នកសម្របសម្រួលបានប្រកាសការពិភាក្សានូវសំណួរ និងចម្លើយនៅក្នុងកិច្ចប្រជុំ។ បន្ទាប់ពីសំណួរ និងចម្លើយបានពិភាក្សារួចហើយ អ្នកសម្របសម្រួលបានប្រកាសពី របៀបវារៈបោះឆ្នោត និងនីតិវិធីបោះឆ្នោត និងបុគ្គលិកទទួលបន្ទុកការបោះឆ្នោតប្រកាសពីរបៀបបោះឆ្នោតទៅកាន់ភាគហ៊ុនិក មុនពេលភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតបានធ្វើការបោះឆ្នោត។ បន្ទាប់មករបាយការណ៍នៃលទ្ធផលបោះឆ្នោតដែលរៀបចំដោយបុគ្គលិកទទួលបន្ទុកការបោះឆ្នោត បានប្រកាសលទ្ធផលបោះឆ្នោតដោយអ្នកសម្របសម្រួលដូចខាងក្រោម៖

| **សេចក្តីសម្រេច៖** អនុម័តលើការបន្តអាណត្តិ ៣ឆ្នាំរបស់អភិបាល ៤រូប ដូចជា | **គាំទ្រ** | **មិនគាំទ្រ** |
|---|---|---|
| **១. លោក នាង វិធី**<br>ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកក្រុមហ៊ុន<br>កាលបរិច្ឆេទតែងតាំង៖ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣<br>កាលបរិច្ឆេទបញ្ចប់អាណត្តិ៖ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៦ | ១៥.៤០៨.៣៩០ ហ៊ុន<br>៩៩,៤៣% | 0 ហ៊ុន<br>0,00% |
| **២. លោកស្រី លឹម មុយលី**<br>អភិបាលប្រតិបត្តិ និងនាយិកាហិរញ្ញវត្ថុ<br>កាលបរិច្ឆេទតែងតាំង៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣<br>កាលបរិច្ឆេទបញ្ចប់អាណត្តិ៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៦ | ១៥.៤០៨.៣៩០ ហ៊ុន<br>៩៩,៤៣% | 0 ហ៊ុន<br>0,00% |
| **៣. លោក ហ៊ុយ វ៉ាថារ៉ូ**<br>អភិបាលឯករាជ្យ<br>កាលបរិច្ឆេទតែងតាំង៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣<br>កាលបរិច្ឆេទបញ្ចប់អាណត្តិ៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៦ | ១៥.៤០៨.៣៩០ ហ៊ុន<br>៩៩,៤៣% | 0 ហ៊ុន<br>0,00% |
| **៤. លោក ថៃ វ៉ាន់ថា**<br>អភិបាលមិនប្រតិបត្តិ<br>កាលបរិច្ឆេទតែងតាំង៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣<br>កាលបរិច្ឆេទបញ្ចប់អាណត្តិ៖ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៦ | ១៥.៤០៨.៣៩០ ហ៊ុន<br>៩៩,៤៣% | 0 ហ៊ុន<br>0,00% |

សរុបសេចក្តីមក កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកបានយល់ព្រមអនុម័តលើសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាភិបាលបានប្រកាសបិទកិច្ចប្រជុំ និងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី២ របស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក បានបញ្ចប់នៅម៉ោង ១០:៤៥ នាទីព្រឹក។

ថ្ងៃអង្គារ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING
Plc.
KINGDOM OF CAMBODIA